# កិច្ចការរបស់យើងចំពោះព្រះ៖ បេសកកម្មរបស់ឪពុកម្ដាយចំពោះជំនាន់កំពុងពេញវ័យ

*អែលឌើរ រ៉ូបឺត ឌី ហែល*
*នៃក្រុមនៃពួកសាវកដប់ពីរនាក់*

នៅរសៀលនេះ ខ្ញុំមានបំណងដើម្បីលើកទឹកចិត្តដល់ពុកម្ដាយទាំងឡាយ និងអស់អ្នកដែលត្រូវបានហៅឲ្យដឹកនាំ និងបម្រើដល់យុវវ័យនៅក្នុងពិភពលោកនេះ។ ព្រះអម្ចាស់បានបើកសម្ដែងដល់យ៉ូសែប ស៊្មីធថា យើងមាន «កាតព្វកិច្ចដ៏ចាំបាច់ដែលយើងមានចំពោះជំនាន់ក្រោយ» (គ. និង ស 123:11)។

ពេញមួយជីវិតរបស់ខ្ញុំក្នុងនាមជាឪពុក និងជាជីតាម្នាក់ ខ្ញុំបានពិចារណានូវសំណួរដែលលើកឡើងថា តើ*កិច្ចការរបស់ខ្ញុំចំពោះព្រះ* ដែលទាក់ទងនឹងពួកយុវវ័យមានអ្វីខ្លះ? តើខ្ញុំអាចចែកចាយអ្វីមួយចំនួនដែលខ្ញុំបានរៀនតាមរយៈការសញ្ជឹងគិត និងទីបន្ទាល់ផ្ទាល់ខ្លួនដែរឬទេ?

ចំពោះយើងគ្រប់គ្នា ការធ្វើកិច្ចការរបស់យើងចំពោះព្រះ ក្នុងនាមជាឪពុកម្ដាយ និងជាអ្នកដឹកនាំ គឺចាប់ផ្ដើមតាមរយៈគំរូ---ដែលជាការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អជាបន្តបន្ទាប់ និងដោយឧស្សាហ៍នៅក្នុងគេហដ្ឋាន។ ការណ៍នេះត្រូវការនូវការប្ដេជ្ញាចិត្ត និងភាពឧស្សាហ៍ប្រចាំថ្ងៃ។

ចំពោះយុវវ័យ គឺគ្មានកត្តាជំនួសណាមួយសម្រាប់ការមើលឃើញ អំពីការរស់នៅតាមដំណឹងល្អនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងឡើយ។ កងពលកម្លោះមិនត្រូវងឿងឆ្ងល់អំពីអ្វីដែលឪពុកម្ដាយរបស់ខ្លួនជឿនោះទេ។ ពួកគេបាននិយាយថា «យើងខ្ញុំមិនសង្ស័យសោះថា ម្ដាយយើងដឹងការណ៍នេះ» (សូមមើល អាលម៉ា 56:47--48)។ តើកូនចៅរបស់យើងដឹងនូវអ្វីដែលយើងដឹងដែរឬទេ?

ខ្ញុំមានចៅប្រុសម្នាក់ដែលនៅគ្រាមួយបានសុំខ្ញុំឲ្យទៅមើលខ្សែភាពយន្តដ៏ល្បីជាមួយនឹងគាត់ ប៉ុន្តែ ខ្សែភាពយន្តនោះមិនសមរម្យឡើយ ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំពុំទាន់គ្រាប់អាយុមើលខ្សែភាពយន្តនោះទេ។ គាត់បានងឿងឆ្ងល់រហូតដល់លោកយាយរបស់គាត់បានពន្យល់ដល់គាត់អំពីអ្វីដែលខ្ញុំចង់មានន័យ។ «លោកតា ឥឡូវនេះចៅយល់ហើយ លោកតានឹងពុំមានអាយុសមល្មមនឹងមើលខ្សែភាពយន្តនោះឡើយមែនទេ?» គាត់គិតត្រូវហើយ!

ក្រៅពីការបង្ហាញផ្លូវដល់យុវវ័យតាមរយៈគំរូ យើងត្រូវដឹកនាំពួកគេតាមរយៈការយល់ដឹងពីដួងចិត្តរបស់ពួកគេ ហើយដើរជាមួយនឹងពួកគេនៅលើផ្លូវនៃដំណឹងល្អ។ ដើម្បីយល់ដួងចិត្តពួកគេឲ្យបានច្បាស់ យើងត្រូវធ្វើអ្វីៗឲ្យបានច្រើនលើសពីការគ្រាន់តែនៅក្នុងបន្ទប់តែមួយ ឬចូលរួមនៅក្នុងសកម្មជាគ្រួសារ និងនៅក្នុងសាសនាចក្រតែមួយ។ យើងត្រូវរៀបផែនការ ហើយក្ដាប់យកឱកាសបង្រៀនដែលធ្វើឲ្យមានចំណាប់អារម្មណ៍ដ៏យូរអង្វែងនៅក្នុងគំនិត និងដួងចិត្តរបស់ពួកគេ។

ឧទាហរណ៍ ពួកអ្នកដឹកនាំសាសនាចក្របានរៀបចំផែនការសម្រាប់ការជួបជុំគ្នា និងការបោះជំរំជាក្រុមកាយឫទ្ធិជាទៀងទាត់---ប៉ុន្តែតើការធ្វើសកម្មភាពទាំងនេះនឹងធ្វើឲ្យម្រេចបាននូវគោលបំណងដ៏សំខាន់បំផុតរបស់ពួកគេដែរឬទេ?

ស្រដៀងគ្នានេះដែរ អ្នកម្ដាយទាំងឡាយ នៅពេលអ្នកបើកបររថយន្ត ឬដើរជូនកូនទៅសាលា ឬសកម្មភាពផ្សេងៗរបស់ពួកគេ តើអ្នកបានប្រើពេលវេលានោះដើម្បីនិយាយនឹងពួកគេអំពីក្ដីសង្ឃឹម ភាពភ័យខ្លាច និងក្ដីអំណររបស់ពួកគេដែរឬទេ?

ការប៉ាន់ប្រមាណហួសពេកអំពីឥទ្ធិពលរបស់ឪពុកម្ដាយដែលយល់ពីដួងចិត្តកូនចៅរបស់ខ្លួន គឺមិនអាចកើតឡើងបានឡើយ។ ការសិក្សាស្រាវជ្រាវបានឲ្យដឹងថា អំឡុងពេលនៃការផ្លាស់ប្ដូរដ៏សំខាន់បំផុតនៅក្នុងជីវិត---រួមទាំងពេលដែលយុវវ័យចង់ឃ្លាតឆ្ងាយចេញពីសាសនាចក្រក្ដី---ឥទ្ធិពលដ៏ធំធេងបំផុតនោះមិនអាចកើតចេញមកពីការសម្ភាសន៍នឹងប៊ីស្សពឡើយ ប៉ុន្តែគឺវាកើតចេញមកពីការស្និទ្ធស្នាលដែលប្រកបដោយភាពកក់ក្ដៅ មានមិត្តភាព និងចេះខ្វល់ខ្វាយជាមួយនឹងឪពុកម្ដាយ។

នៅពេលយើងអង្គុយនៅតុអាហារពេលល្ងាចដោយមានការណ៍នោះក្នុងគំនិត តើគ្រួសារទាំងមូលរបស់យើងនៅទីនោះដែរឬទេ? កាលពីនៅក្មេងខ្ញុំនៅចាំពីការសុំការអនុញ្ញាតទៅលេងកីឡាវាយកូនបាល់នៅពេលអាហារពេលល្ងាច។ ខ្ញុំបាននិយាយទៅកាន់អ្នកម្ដាយរបស់ខ្ញុំថា «សូមទុកអាហាររបស់កូននៅក្នុងទូចុះ»។ គាត់បានឆ្លើយតបវិញថា ឌី រ៉ូប៊ឺត ម៉ាក់ចង់ឲ្យកូនសម្រាក ហើយត្រឡប់មកផ្ទះញ៉ាំអាហារពេលល្ងាចជាមួយគ្នាសិន ហើយបន្ទាប់ពីនោះកូនអាចទៅលេងរហូតដល់យប់ក៏បានដែរ»។ គាត់បានបង្រៀនដល់យើងគ្រប់គ្នាថា កង្វល់ចំពោះការបរិភោគអាហារជាគ្រួសារ គឺពុំមែនទាក់ទងនឹងបញ្ហាម្ហូបឡើយ ប៉ុន្តែគឺជាភាពស្និទ្ធស្នាលក្នុងគ្រួសារដែលអាចចិញ្ចឹមបីបាច់ដល់ដួងព្រលឹងរបស់យើង។ សេចក្ដីស្រឡាញ់ដ៏ធំបំផុតដែលយើងត្រូវផ្ដល់គឺស្ថិតនៅក្នុងរង្វង់គ្រួសាររបស់យើង។

សម្រាប់ភាពស្និទ្ធស្នាលជាមួយនឹងយុវវ័យដើម្បីធ្វើឲ្យមានការដក់ជាប់នៅក្នុងដួងចិត្តរបស់ពួកគេ យើងត្រូវតែយកចិត្តទុកដាក់ទៅលើពួកគេ ដូចដែលយើងធ្វើចំពោះមិត្តរួមការងារដែលគួរឲ្យទុកចិត្ត ឬមិត្តដ៏ជិតស្និទ្ធម្នាក់ដែរ។ សំខាន់បំផុត គឺការសួរសំណួរពួកគេ ការអនុញ្ញាតឲ្យពួកគេបញ្ចេញយោបល់ បន្ទាប់មកត្រងត្រាប់ស្ដាប់ គឺស្ដាប់ជាមួយនឹងត្រចៀកខាងវិញ្ញាណ។ កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំបានអានសារព័ត៌មានមួយ ខណៈដែលចៅប្រុសរបស់ខ្ញុំម្នាក់អង្គុយនៅក្បែរនោះ។ នៅពេលខ្ញុំអាន ខ្ញុំបានឮសម្លេងដ៏ផ្អែមល្ហែមរបស់គាត់និយាយតាមពីក្រោយ។ ប៉ុន្មាននាទីក្រោយមក ខ្ញុំមានការភ្ញាក់ផ្អើលនៅពេលគាត់បានរុញខ្លួនឯងចុះឡើងនៅចន្លោះក្រដាសសារព័ត៌មាននោះ និងរូបខ្ញុំ។ ដោយយកដៃរបស់គាត់ចាប់មុខរបស់ខ្ញុំ ហើយយកច្រមុះរបស់គាត់ប៉ះនឹងច្រមុះរបស់ខ្ញុំ នោះគាត់បានសួរថា «លោកតា! តើលោកតា

បានស្តាប់ចៅទេ?»

ម៉ាក់ ប៉ា តើលោកទាំងពីរបានស្តាប់កូនទេ? លោកតាលោកយាយ តើលោកទាំងពីរបានស្តាប់កូនទេ? ការស្តាប់គឺមានន័យថា ការយល់ពីចិត្តនៃយុវវ័យរបស់យើង និងមានទំនាក់ទំនងនឹងពួកគេ។ ហើយការមានទំនាក់ទំនងនឹងពួកគេពុំមែនគ្រាន់តែជាការសន្ទនាជាមួយនឹងពួកគេនោះទេ ប៉ុន្តែវារួមផ្សំនឹងការធ្វើកិច្ចការទាំងឡាយជាមួយនឹងពួកគេផងដែរ។

ថ្មីៗនេះ ខ្ញុំបានស្តាប់ឮអ្នកម្តាយរបស់ខ្ញុំរៀបរាប់ឡើងវិញពីរបៀបដែលគាត់ជួយដល់កូនស្រីបីនាក់ដំបូងរបស់ខ្លួនឲ្យបំពេញកិច្ចការនៅក្នុងការពង្រឹងខ្លួននៃក្រុមយុវនារី តាមរយៈការធ្វើនូវអ្វីដែលបានរំពឹងទុក---ដោយការទទួលចំណេះដឹង និងការបញ្ចប់គម្រោងនានា។ បន្ទាប់មក គាត់បានពន្យល់ដោយក្តីស្រឡាញ់ថា «ថ្មីៗនេះ ម៉ាក់បានធ្វើការជាមួយនឹងកូនស្រីទីបួនរបស់ម៉ាក់ដោយការធ្វើកិច្ចការរបស់នាងជាមួយគ្នា។ វាបានធ្វើឲ្យជីវិត និងទំនាក់ទំនងរបស់យើងមានការផ្លាស់ប្តូរ។ ប៉ុន្តែ ខ្ញុំមានអារម្មណ៍សោកស្តាយ នៅពេលខ្ញុំដឹងពីអ្វីដែលខ្ញុំបានបាត់បង់ ដោយការមិនបានធ្វើកិច្ចការនេះជាមួយនឹងកូនស្រីរបស់ខ្ញុំបីនាក់ទៀត»។

សមាជិកសាសនាចក្រដែលមានវ័យចំណាស់គួរយល់ថា យោបល់នៅក្នុងកម្មវិធីការអភិវឌ្ឍន៍ខ្លួននៃក្រុមយុវនារី និងកិច្ចការចំពោះព្រះ គឺពុំមែនជាបញ្ជីដ៏វែងដែលគ្រាន់តែគូសធីកនោះឡើយ។ វាគឺជាគោលដៅដែលធ្វើឡើងដោយយុវជន និងយុវនារីម្នាក់ៗដើម្បីជួយពួកគេឲ្យមានភាពសក្តិសម ដើម្បីទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ បំពេញបេសកកម្ម ចូលទៅក្នុងអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច ហើយរីករាយនឹងភាពដំកើងឡើង។ *ប៉ុន្តែ សូមយល់ថា៖ ការដែលយុវជនយុវនារីព្យាយាមសម្រេចគោលដៅទាំងនេះតែម្នាក់ឯង នោះវាគឺការបាត់បង់ និងជាសោកនាដកម្មដ៏ធំមួយ!* ឪពុកម្តាយទាំងឡាយ ព្រមទាំងពួកអ្នកដឹកនាំយុវជនផងដែរ យើងសូមលើកទឹកចិត្តដល់អ្នករាល់គ្នាឲ្យចូលរួមចំណែកនៅក្នុងកម្មវិធីការពង្រីកខ្លួននៃក្រុមយុវនារី និងកិច្ចការចំពោះព្រះជាមួយនិងពួកយុវវ័យរបស់អ្នក។ ពុំមែនតែពួកគេម្នាក់ឯងដែលនឹងរីកចម្រើននោះទេ គឺរួមទាំងអ្នកផងដែរ។ ហើយសំខាន់ជាងនេះទៀត អ្នកនឹងរីកចម្រើនរួមគ្នានៅក្នុងចំណងនៃសេចក្តីជំនឿ និងមិត្តភាពមួយដែលនឹងអនុញ្ញាតឲ្យអ្នកជួយពង្រឹងគ្នាទៅវិញទៅមក ហើយបន្តដើរនៅលើផ្លូវនៃដំណឹងល្អជារៀងរហូត។

ផ្នែកដ៏សំខាន់បំផុតមួយនៅក្នុងការបំពេញកិច្ចការរបស់យើងចំពោះព្រះក្នុងនាមជាឪពុកម្តាយ គឺការបង្រៀនកូនចៅរបស់យើងអំពីដំណឹងល្អ និងការរៀបចំពួកគេឲ្យចូលរួមយ៉ាងក្លៀវក្លានៅក្នុងសាសនាចក្រដែលបានស្តារឡើងវិញរបស់ព្រះអង្គសង្គ្រោះ។ សូមចងចាំពីមេរៀននៃរាស្ត្ររបស់ស្តេចបេនយ៉ាមីន។ ជាលទ្ធផលនៃបង្រៀនរបស់ទ្រង់ នោះមានមនុស្សវ័យចំណាស់ជាច្រើនបានមានការផ្លាស់ប្តូរដ៏ធំនៅក្នុងដួងចិត្ត។ ប៉ុន្តែ ឪមានមនុស្សជាច្រើននៃជំនាន់ដែលកំពុងពេញវ័យដែលពុំអាចយល់នូវពាក្យពេចន៍នៃស្តេចបេនយ៉ាមីនបានឡើយ ដោយខ្លួននៅក្មេងពេកក្នុងកាលទ្រង់បានមានបន្ទូលទៅកាន់ប្រជាជនទ្រង់ ហើយ

ពួកគេពុំបានជឿ។ ឯចិត្តគេត្រឡប់ជារឹងរូសទៅវិញ 9 ម៉ូសាយ 26:13។

វាគឺជាកិច្ចការដ៏សំខាន់របស់យើងនៅក្នុងការជួយពួកយុវវ័យឲ្យយល់ ហើយជឿលើដំណឹងល្អស្របតាមវិធីផ្ទាល់ខ្លួនមួយដែលមានលក្ខណៈស៊ីជំរៅ។ យើងអាចបង្រៀនពួកគេឲ្យដើរនៅក្នុងពន្លឺ ហើយជាពន្លឺដែលមិនអាចខ្ចីបានឡើយ។ ពួកគេត្រូវតែទទួលបាន ពន្លឺនៃទីបន្ទាល់ដោយខ្លួនឯង មកពីប្រភពនៃពន្លឺខាងវិញ្ញាណ---ជាព្រះផ្ទាល់។ ពួកគេត្រូវយល់ពីអត្តសញ្ញាណរបស់ខ្លួន និងអ្វីដែលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យពួកគេធ្វើ។ តើយើងជួយពួកគេតាមរបៀបណា?

នៅពេលយើងធ្វើរាត្រីជួបជុំក្រុមគ្រួសារ ការប្រឹក្សាក្នុងគ្រួសារ  ឬការសន្ទនាអំពីដំណឹងល្អដ៏មានអត្ថន័យមួយ ជាមួយនិងកូនចៅរបស់យើង នោះយើងមានឱកាសដើម្បីសម្លឹងមើលភ្នែករបស់ពួកគេ ហើយប្រាប់ពួកគេថា យើងស្រឡាញ់ពួកគេ ហើយថាព្រះវរបិតាសួគ៌ស្រឡាញ់ពួកគេ។ នៅក្នុងបរិយាកាសដ៏ពិសិដ្ឋទាំងនេះ យើងក៏អាចជួយពួកគេឲ្យយល់ស៊ីជំរៅក្នុងដួងចិត្តរបស់គេអំពីអត្តសញ្ញាណរបស់ខ្លួន ហើយថាតើពួកគេមានភ័ព្វសំណាងប៉ុណ្ណាដែលបានមកកាន់ផែនដីនេះ ហើយរស់នៅក្នុងគ្រួសាររបស់យើងនោះ។ នៅរាល់ការប្រាស្រ័យទាក់ទង យើងអាចចែកចាយ ឬបង្ហាញអំពីគោលការណ៍ និងពរជ័យនៃដំណឹងល្អ។ នៅក្នុងពេលវេលាដ៏មានតម្លៃទាំងនេះ ការដែលគ្រាន់តែ*ដឹង* គឺវាពុំគ្រប់គ្រាន់ចំពោះពួកយុវវ័យរបស់យើងឡើយ។ ពួកគេត្រូវតែ*ធ្វើ*។ ការចូលរួមចំណែកដោយអស់ពីចិត្តនៅក្នុងពិធីបរិសុទ្ធនានា ក្នុងក្រុម និងអង្គការជំនួយ ក្នុងកម្មវិធីដែលបំផុសគំនិត សកម្មភាពល្អៗជួយពួកយុវវ័យរបស់យើងឲ្យពាក់នូវគ្រឿងសឹកនៃព្រះ។ តើអ្នកនឹងជួយពួកគេឲ្យពាក់នូវគ្រឿងសឹកនោះ ដើម្បីពួកគេអាចតតាំងនឹងព្រួញភ្លើងទាំងឡាយរបស់មាសត្រូវដែរឬទេ? ដើម្បីជ្រើសយកផ្លូវរបស់ព្រះអម្ចាស់ ពួកគេត្រូវស្គាល់ពីផ្លូវរបស់ទ្រង់។ ហើយដើម្បីស្គាល់ពីផ្លូវរបស់ទ្រង់ យើងត្រូវបង្រៀន ហើយដឹកនាំពួកគេឲ្យអនុវត្ត ចូលរួមចំណែក និងធ្វើអ្វីដែលត្រឹមត្រូវ។

ការបង្រៀន និងការដឹកនាំជំនាន់ដែលកំពុងពេញវ័យតម្រូវឲ្យមានការដាក់ផែនការ និងកិច្ចខិតខំដ៏ឧស្សាហ៍ព្យាយាម។ ឧទាហរណ៍ តើយើងរៀបចំគ្រួសាររបស់យើងឲ្យចូលរួមចំណែកនៅក្នុងពិធីបរិសុទ្ធនៃសាក្រាម៉ង់ជារៀងរាល់សប្តាហ៍ដែរឬទេ? តើយើងរៀបចំពួកគេឲ្យចូលរួមនៅក្នុងការសម្ភាសន៍ជង្វាយមួយភាគក្នុងដប់ជាមួយនិងយើងដែរឬទេ? តើយើងរៀបចំពួកគេសម្រាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជន និងថ្នាក់សិក្ខាសាលាដែរឬទេ? តើយើងកំពុងរៀបចំពួកគេសម្រាប់ព្រះវិហារបរិសុទ្ធ---ដោយពុំមែនគ្រាន់ជាអ្វីមួយដែលធ្វើឡើងដើម្បីបម្រើបេសកកម្មពេញម៉ោង ឬអាពាហ៍ពិពាហ៍នោះទេ ប៉ុន្តែជាការតាំងចិត្តមួយដែរឬទេ?

នៅក្នុងការរៀបចំខាងដំណឹងល្អនេះ យើងគួរចងចាំថា សាសនាចក្រ និងកម្មវិធីទាំងឡាយរបស់ខ្លួនគឺជាដៃគូដ៏ល្អបំផុតរបស់យើង។ វាពុំមែនប្រកួតប្រជែងនឹងគ្រួសារសម្រាប់ពេលវេលា និងចំណាប់អារម្មណ៍

ពីសំណាក់ពួកយុវវ័យនោះទេ។ ផ្ទុយទៅវិញ អង្គការបឋមសិក្សា ថ្នាក់សាលាថ្ងៃអាទិត្យ ក្រុមបព្វជិតភាព អើរ៉ុន និងថ្នាក់យុវនារី គឺត្រូវបានបង្កើតឡើងដើម្បីជួយដល់ពួកយុវវ័យឲ្យមានការទទួលខុសត្រូវនៅក្នុងគេហដ្ឋាន ការគោរពប្រតិបត្តិ គារវភាព និងសេចក្ដីស្រឡាញ់ និងភាពស្មោះត្រង់កាន់តែច្រើនឡើងក្នុងនាមជាអ្នកតំណាងរបស់ព្រះគ្រីស្ទនៅក្នុងពិភពលោកនេះ និងធ្វើជាឪពុកម្ដាយដ៏មានប្រសិទ្ធភាពនាពេលអនាគត។ ការណ៍ទាំងនេះ ពុំមែនជាបន្ទុកមកលើយើងឡើយ លើកលែងតែយើងមិនបានយល់ពីគោលបំណងរបស់វាប៉ុណ្ណោះ។ ក្នុងនាមជាឪពុកម្ដាយ នៅពេលយើងយល់ពីគោលបំណងទាំងនោះ ហើយប្រើវាដើម្បីជួយយើង នោះវានឹងក្លាយទៅជាធនធាន និងពរជ័យដ៏មានតម្លៃមួយ។

នៅក្នុងការហៅរបស់ខ្ញុំ ខ្ញុំបាននិយាយនឹងសមាជិកជាច្រើន ជាអ្នកដែលបានបម្រើជាអ្នក ផ្សព្វផ្សាយសាសនាវ័យចំណាស់យូរហើយ។ មានមួយចំនួនបានបម្រើបេសកកម្មកាលពីនៅជាយុវវ័យ ហើយចង់បម្រើម្ដងទៀត។ យើងត្រូវការជាអ្នកផ្សព្វផ្សាយសាសនាវ័យចំណាស់ច្រើន។ ប៉ុន្តែ បងប្អូនប្រុសស្រីរបស់ខ្ញុំ---ដែលជាឪពុកម្ដាយ និងជាអ្នកដឹកនាំនៃជំនាន់ដែលកំពុងពេញវ័យអើយ--- ទោះបីជាបេសកកម្ម ពេញម៉ោងក៏ដោយ ក៏តម្លៃដ៏មហិមានៅក្នុងពេលពីរបីខែនេះអាចមានភាពយូរអង្វែង អាទិភាពដ៏យូរអង្វែងរបស់យើងជាអ្នកផ្សព្វផ្សាយសាសនា គឺជាការផ្លាស់ប្រែចិត្តកូនចៅរបស់យើងផ្ទាល់  និងពួកយុវវ័យនៃសាសនាចក្រ។  គេហដ្ឋាន ក្រុម និងថ្នាក់របស់យើង ក៏ជាចំណែកនៃតំបន់បេសកកម្មរបស់យើងផងដែរ។ កូន និងចៅរបស់យើង គឺជាពួកអ្នករៀនដ៏សំខាន់បំផុតរបស់យើង។ កិច្ចការផ្សព្វផ្សាយសាសនាដ៏ធំបំផុតដែលយើងពុំធ្លាប់ធ្វើពីមុនមក គឺស្ថិតនៅក្នុងគេហដ្ឋានរបស់យើងផ្ទាល់។ ឧទាហរណ៍ បើនរណាម្នាក់ នៅក្នុងគ្រួសាររបស់អ្នក កំពុងវង្វេងនៅតាមផ្លូវចម្លែក អ្នកក៏អាចធ្វើជាអ្នកជួយសង្គ្រោះផងដែរ ដោយការចូលរួមចំណែកនៅក្នុងកិច្ចការជួយសង្គ្រោះដ៏ធំបំផុត ដែលសាសនាចក្រពុំធ្លាប់មានពីមុនមក។ នៅក្នុងកិច្ចការនេះ សូមធ្វើតាមគំរូដែលប្រកបដោយការបំផុសគំនិតរបស់លីហៃ និងសារ៉ា។ សូមចងចាំថា  លីហៃបានសម្លឹងមើលទៅលើផ្លូវនោះដោយក្ដីព្រួយបារម្ភថា «ប្រហែលជា» លេមិន លេមយួលនឹងមានសេចក្ដីស្មោះត្រង់ ហើយធ្វើតាម។ គាត់គ្មានការជឿជាក់ថា ពួកគេនឹងត្រឡប់មកវិញឡើយ ប៉ុន្តែគាត់នៅតែបន្តបង្រៀនពួកគេ «ដោយអស់ទាំងអារម្មណ៍របស់មេបាដ៏ទន់ភ្លន់ម្នាក់»។

បើកូនចៅរបស់អ្នកបានដើរផ្លូវខុស  សូមសម្លឹងមើលទៅផ្លូវនោះ ហើយចោលភ្នែករបស់អ្នករំពៃរកពួកគេ។ សូមធ្វើដូចជាឪពុកនៃកូនប្រុសដែលខ្ជះខ្ជាយ ដែលបានរៀបខ្លួនជាស្រេចក្នុងការរត់ទៅរកពួកគេ ហើយឱបពួកគេតាមរបៀបដែលពួកគេនឹងទទួលយក។ សូមបង្រៀន ថ្លែងទីបន្ទាល់  ចែកចាយ និងលើកទឹកចិត្តពួកគេដោយអស់ទាំងអារម្មណ៍របស់ឪពុកម្ដាយដ៏ទន់ភ្លន់ម្នាក់។

ខ្ញុំសូមថ្លែងទីបន្ទាល់តាមរយៈបទពិសោធន៍ផ្ទាល់របស់ខ្ញុំថា៖ ភាពបរាជ័យនៅក្នុងជីវិតនេះកើតឡើងនៅពេលអ្នកព្រមចុះចាញ់ប៉ុណ្ណោះ។ វាពុំដែលលឿនពេក ឬយឺតពេកដើម្បីចាប់ផ្ដើមនោះឡើយ។ កុំបារម្ភចំពោះអ្វីដែលកើតឡើងកាលពីមុន។ សូមធ្វើការហៅទូរស័ព្ទ។ សូមសរសេរលិខិតខ្លីមួយ។ សួរសុខទុក្ខ។

សូមធ្វើការអញ្ជើញឲ្យត្រឡប់មកគេហដ្ឋាន។ សូមកុំមានការភ័យខ្លាច ឬអៀនខ្មាស់។ កូនរបស់អ្នកគឺជាកូនរបស់ព្រះវរបិតាសួគ៌។ អ្នកកំពុងធ្វើកិច្ចការរបស់ទ្រង់។ ទ្រង់បានសន្យាថានឹងប្រមូលផ្ដុំកូនចៅរបស់អ្នក ហើយទ្រង់នឹងគង់នៅជាមួយអ្នក។ ប្រធានម៉នសុន បានលើកទឹកចិត្តយើងឲ្យធ្វើជាមនុស្សរឹងមាំ។ សេចក្ដីជំនឿដ៏ធំធេងបំផុតដែលយើងមាននឹងស្ថិតនៅក្នុងគេហដ្ឋានរបស់យើង ដរាបណាយើងបន្តមានភាពរឹងមាំនៅក្នុងការសាកល្បង និងក្នុងភាពលំបាកក្នុងនាមជាឪពុកម្ដាយ។

យើងគ្រប់គ្នាអាចត្រូវបានលើកទឹកចិត្តនៅក្នុងអំណាចខាងវិញ្ញាណថា បើយើងពិតរស់នៅតាមសេចក្ដីសញ្ញាទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ នោះសេចក្ដីសញ្ញាអាចមានមកលើកូនចៅរបស់យើង។ បើអ្នកមិនបានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ សូមធ្វើកិច្ចការនោះដើម្បីជាប្រយោជន៍ដល់ខ្លួនអ្នក និងសមាជិកគ្រួសាររបស់អ្នក។ នៅពេលអ្នកទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ អ្នកនឹងត្រូវបានប្រទានឲ្យនូវអំណាចមកពីស្ថានសួគ៌ដើម្បីអ្នកអាចប្រឈមមុខនឹងឧបសគ្គដោយមានទំនុកចិត្ត និងដោយក្ដីអំណរ។ យើងបានខិតខំធ្វើកិច្ចការពង្សប្រវត្តិដើម្បីយើងអាចធ្វើពិធីបរិសុទ្ធដ៏ពិសិដ្ឋនៃការសង្គ្រោះដល់ដូនតារបស់យើង។ ប៉ុន្តែ កិច្ចការពង្សប្រវត្តិដ៏ធំបំផុតដែលយើងនឹងធ្វើ គឺជាការរៀបចំកូនចៅរបស់យើងខាងវិញ្ញាណនៅក្នុងជំនាន់ដែលកំពុងពេញវ័យ ដែលនឹងធានាដល់ការរក្សាទុក និងការបន្តដ៏នៅអស់កល្បជានិច្ចនៃគ្រួសាររបស់យើងសម្រាប់ជំនាន់ក្រោយ តាមរយៈការគោរពប្រតិបត្តិរបស់ពួកគេ។

ថ្មីៗនេះ ប្រធានម៉នសុនបានមានប្រសាសន៍ទៅកាន់ពួកអ្នកម្ដាយមួយក្រុមតូចថា «ពេលខ្លះ យើងឆាប់វិនិច្ឆ័យពេកទៅលើផលប៉ះពាល់នៃភាពជោគជ័យ និងការបរាជ័យរបស់យើង»។ ខ្ញុំសូមបន្ថែមទៀតថា សូមកុំគិតថាការសាកល្បងនៅថ្ងៃនេះគឺជារឿងដ៏នៅអស់កល្បជានិច្ចឲ្យសោះ។ ព្រះវរបិតាសួគ៌គឺធ្វើកិច្ចការរបស់ទ្រង់នៅក្នុងរយៈពេលវែង។ ព្យាការីយ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា «មានការណ៍ជាច្រើននៅអនាគត... ហេតុដូច្នេះហើយ...ចូរយើងប្រព្រឹត្តការណ៍ទាំងនេះ ដែលនៅក្នុងអំណាចយើងដោយមានចិត្តរីករាយចុះ ហើយលំដាប់នោះយើងអាចឈរនៅស្ងៀមដោយជឿជាក់ថានឹងបានឃើញសេចក្ដីសង្គ្រោះពីព្រះ និងបានព្រះពាហុទ្រង់បើកសម្ដែងមកឲ្យឃើញ» (គ. និង ស. 123:15, 17)។

ខ្ញុំសូមថ្លែងនូវទីបន្ទាល់ពិសេសរបស់ខ្ញុំថា ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់។ ទ្រង់គឺអ្នកគង្វាលចៀមដែលវង្វេងផ្លូវ ជាអ្នកជួយសង្គ្រោះដល់ដួងព្រលឹងដែលជាប់ចំណង ជាអ្នកព្យាបាលដល់ដួងចិត្តដែលមានរបួស និងជាសេចក្ដីសង្ឃឹមនៃមនុស្សលោកគ្រប់រូប។ ដោយមានទ្រង់ធ្វើជាលោកចៅហ្វាយរបស់យើង ចូរយើងបំពេញកិច្ចការរបស់យើងចំពោះព្រះដោយសេចក្ដីជំនឿទៅលើទ្រង់ និងសេចក្ដីស្រឡាញ់ដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ចំពោះយើងម្នាក់ៗ ខ្ញុំអធិស្ឋាននៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។